ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ស្ថានឯកអគ្គរាជទូតកម្ពុជា
ប្រចាំប្រទេសបារាំង

លេខ ១៦៣ -២០២១/ARC/AG

# សេចក្តីជូនដំណឹង

ស្ថានឯកអគ្គរាជទូតកម្ពុជានៅទីក្រុងប៉ារីស សូមជម្រាបជូនប្រជាពលរដ្ឋ សិស្ស និងនិស្សិតខ្មែរ **ទាំងអស់**ថា ចាប់ពីថ្ងៃពុធ ទី៩ ខែមិថុនា ឆ្នាំ២០២១ រដ្ឋាភិបាលបារាំងនឹងចាប់ផ្តើមបន្ធូរបន្ថយវិធានការរឹតត្បិតការធ្វើដំណើរចេញ-ចូលប្រទេសបារាំង ដោយផ្អែកលើស្ថានភាពនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងការចាក់វ៉ាក់សាំងរបស់អ្នកធ្វើដំណើរ នៃប្រទេសគោលដៅ និងប្រទេសចេញដំណើរ។

ដោយបច្ចុប្បន្ន ប្រទេសកម្ពុជាត្រូវបានចាត់ចូលជាក្រុមប្រទេសពណ៌ទឹកក្រូច (១) លក្ខខណ្ឌខាងក្រោម នឹងត្រូវអនុវត្តៈ

1. ចំពោះអ្នកដំណើរដែលទទួលបានវ៉ាក់សាំងពេញលេញ (២)

➢ **ការធ្វើដំណើរចាកចេញពីប្រទេសបារាំង** ទៅកម្ពុជា៖
- ពុំតម្រូវឱ្យមានលិខិតបញ្ជាក់ពីមូលហេតុចាំបាច់បំផុតទេ
- តែត្រូវធ្វើតេស្តិ៍អវិជ្ជមានកូវីដ-១៩ (PCR) ក្រោម ៧២ ម៉ោង មុនធ្វើដំណើរ និងធ្វើតេស្តិ៍នេះបន្ថែមទៀត ពេលទៅដល់កម្ពុជា។
- និងធ្វើចត្តាឡីស័កចំនួន ១៤ថ្ងៃ ដដែល។

➢ **ការធ្វើដំណើរពីប្រទេសកម្ពុជា ចូលមកប្រទេសបារាំង**៖
- ពុំតម្រូវឱ្យមានលិខិតបញ្ជាក់ពីមូលហេតុចាំបាច់បំផុតទេ
- តែតម្រូវឱ្យធ្វើតេស្តិ៍អវិជ្ជមានកូវីដ-១៩ (PCR) ក្រោម៧២ម៉ោង ឬការធ្វើតេស្តិ៍លឿន (Antigénique) ក្រោម៤៨ម៉ោង មុនពេលឡើងយន្តហោះ
- ត្រូវដាក់ខ្លួននៅដាច់ដោយឡែករយៈពេល៧ថ្ងៃនៅពេលទៅដល់ប្រទេសបារាំង។

2. ចំពោះអ្នកដំណើរដែលមិនទាន់បានចាក់វ៉ាក់សាំង
- ត្រូវបង្ហាញនូវហេតុផលចាំបាច់បំផុតដើម្បីធ្វើដំណើរទៅប្រទេសបារាំង និងលទ្ធផលតេស្តិ៍អវិជ្ជមានកូវីដ-១៩ (PCR) ក្រោម៧២ម៉ោង ឬការធ្វើតេស្តិ៍លឿន ក្រោម៤៨ម៉ោង
- ការធ្វើតេស្តិ៍អាចធ្វើឡើងផងដែរនៅពេលទៅដល់ប្រទេសបារាំង
- និងត្រូវដាក់ខ្លួននៅដាច់ដោយឡែករយៈពេល ៧ថ្ងៃ នៅពេលមកដល់ប្រទេសបារាំង។

4, rue Adolphe Yvon
75116 – PARIS (France)
Tel. : (33) 01 45 03 47 20
Fax : (33) 01 45 03 47 40

ទន្ទឹមនឹងនេះ អនុលោមតាមវិធានការបើកប្រទេសឡើងវិញរបស់រដ្ឋាភិបាលបារាំង ស្ថានឯកអគ្គរាជទូតកម្ពុជានៅទីក្រុងប៉ារីស នឹងចាប់ផ្តើមផ្តល់សេវាកម្មកុងស៊ុល តាមពេលវេលាពេញលេញឡើងវិញ ចាប់ពីថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២១ គឺរយៈពេល៥ថ្ងៃ ក្នុង១សប្តាហ៍ ពីថ្ងៃចន្ទ ដល់ សុក្រ ពេលព្រឹក ពីម៉ោង ០៩:០០នាទី ដល់ម៉ោង១២:០០នាទី និងពេលរសៀល ពីម៉ោង១៤:០០នាទី ដល់ម៉ោង ១៦:០០នាទី ។

ក្រៅពីពេលវេលាដូចបានកំណត់ខាងលើ សូមទាក់ទងមកលោក **សាលី ម៉ាលីវ៉ាត់** កុងស៊ុល តាមលេខទូរស័ព្ទ (+33) 1 45 03 47 20 និងអាសយដ្ឋានអ៊ីម៉ែល arc@ambcambodgeparis.info ។

ថ្ងៃពុធ ១៤រោច ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
ប៉ារីស ថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ២០២១

(១) ប្រទេសនានាត្រូវបានចាត់ថ្នាក់ពណ៌«បៃតង» «ទឹកក្រូច» ឬ«ក្រហម

(២)

- ❖ វ៉ាក់សាំងដែលទទួលស្គាល់ដោយប្រទេសបារាំង រួមមាន៖ Pfizer, Moderna, AstraZeneca et Johnson et Johnson)។
- ❖ ការចាក់វ៉ាក់សាំងត្រូវបានចាត់ទុកថាពេញលេញនៅពេល៖
  - ២សប្តាហ៍បន្ទាប់ពីការចាក់លើកទី២ សម្រាប់វ៉ាក់សាំង (Pfizer, Moderna, AstraZeneca)
  - ៤សប្តាហ៍បន្ទាប់ពីការចាក់វ៉ាក់សាំងតែមួយដង សម្រាប់វ៉ាក់សាំង (Johnson & Johnson)
  - ២សប្តាហ៍បន្ទាប់ពីការចាក់វ៉ាក់សាំងតែមួយដង (សម្រាប់បុគ្គលដែលធ្លាប់មានជំងឺកូវីដ-១៩)។